# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីអំណាចទាំងបី គឺអំណាចរដ្ឋសភា អំណាចរដ្ឋាភិបាល
## និងអំណាចតុលាការ សំរាប់ប្រទេសកម្ពុជា
## និងអំពីសន្ធិសញ្ញាបន្ថែម

**web site ៖ hoksavann.org**

ថ្ងៃទី១៥ វិច្ឆិកា ២០០៥

ប្រទេសដែលកាន់របបប្រជាធិបតេយ្យ ដែលពុំមែនជារបបកុម្មុយនិស្ត អំណាចទាំងបីគឺ អំណាចនីតិបញ្ញត្តិ (រដ្ឋសភា) អំណាចនីតិប្រតិបត្តិ (រដ្ឋាភិបាល) និងអំណាចតុលាការ តែងចែកដាច់ពីគ្នា ហើយមានឯករាជ្យរៀងខ្លួន ។ ស្របនិងព្រះពុទ្ធសាសនា ព្រះវិន័យដែលព្រះពុទ្ធបានបញ្ញត្តិនិងអនុញ្ញាតទុកជានីតិបញ្ញត្តិ ព្រះសង្ឃបានអនុវត្តតាមទុកជានីតិប្រតិបត្តិ, ព្រះថេរសភាសង្ឃ ឬព្រះវិន័យធរសង្ឃកាត់សេចក្តីនៅពេលដែលព្រះសង្ឃប្រព្រឹត្តខុស ចាត់ជាតុលាការ ។ ព្រះសង្ឃមិនអាចកែប្រែព្រះវិន័យ ហើយព្រះសង្ឃជាអ្នកកាត់សេចក្តីប្រកបដោយយុត្តិធម៌ ពុំលំអៀងដោយយកព្រះវិន័យជាគោល ក្នុងការកាត់សេចក្តី ។ ចំពោះរបបប្រជាធិបតេយ្យនៃផ្លូវអាណាចក្រ អំណាចទាំងបីកើតចេញមកពីប្រជាពលរដ្ឋ តាមរយៈសន្លឹកឆ្នោតឲ្យគ្រប់គ្រងប្រទេសឲ្យមានសន្តិភាពនិងវឌ្ឍនភាព ។ អំណាចនីតិបញ្ញត្តិជាអ្នកតាក់តែងច្បាប់ អំណាចនីតិប្រតិបត្តិជាអ្នកអនុវត្តច្បាប់ និងអំណាចតុលាការ ជាអ្នកផ្តល់យុត្តិធម៌ឲ្យអ្នកគោរពច្បាប់ និងអ្នកពុំគោរពច្បាប់ ។ ស្ថាប័នទាំងបីនេះ គេតែងញែកឲ្យដាច់ពីគ្នា ដោយពុំឲ្យស្ថាប័នណារំលោភលើស្ថាប័នណាឡើយ ។

តាមយើងសង្កេតឃើញ អំណាចទាំងបីនៅប្រទេសកម្ពុជាបច្ចុប្បន្នហាក់ដូចជានៅច្របូកច្របល់គ្នា គឺអំណាចរដ្ឋសភានិងអំណាចតុលាការ ហាក់ដូចជានៅក្រោមអំណាចរដ្ឋាភិបាល ។

ដើម្បីទាញអំណាចរដ្ឋសភាឲ្យនៅក្រោមអំណាចខ្លួន រដ្ឋាភិបាលបានតែងតាំងតំណែងមួយទៀតឲ្យប្រធានរដ្ឋសភា ធ្វើជាទីប្រឹក្សាពិសេសនៃរាជរដ្ឋាភិបាល ។ ប្រធានរដ្ឋសភានិងនាយករដ្ឋមន្ត្រីតែងតែទូរស័ព្ទពិគ្រោះគ្នាជានិច្ច ចំពោះកិច្ចការរដ្ឋាភិ

បាល ។ ដូច្នេះ គេពុំឃើញប្រធានរដ្ឋសភាមានមតិជំទាស់ចំពោះសេចក្តីស្នើច្បាប់ណាមួយ ដែលរដ្ឋាភិបាលចង់បាន បានសេចក្តីថា ប្រធានរដ្ឋសភាតែងតែយល់ស្របជានិច្ច ដូចជាច្បាប់រដ្ឋាភិបាលកញ្ចប់ ច្បាប់អនុសញ្ញាបំពេញបន្ថែមឆ្នាំ១៩៨៥ជាដើម ។ គឺគេទាញតែប្រធានរដ្ឋសភាម្នាក់បាន សមាជិកសភានៃគណបក្សនោះនឹងបង្ខំចិត្តធ្វើតាម ព្រោះការបោះឆ្នោតជាសមាមាត្រ អំណាចនៅលើប្រធានបក្សតែងតាំងតំណាងរាស្ត្រឲ្យធ្វើជាសមាជិកសភា បើប្រធានបក្សមិនពេញចិត្ត អាចដកតំណាងរាស្ត្រនោះចេញពីសមាជិកសភា ។ ដូច្នេះអំណាចរដ្ឋសភាស្ថិតនៅក្រោមការអូសទាញរបស់រដ្ឋាភិបាល ។ ចំពោះអំណាចតុលាការវិញ យើងសង្កេតឃើញថានៅពេលដែលមានបណ្តឹងពីរដ្ឋាភិបាល តុលាការតែងតែចាត់ការភ្លាម ដូចជាការចាប់សកម្មជននៃគណបក្សប្រឆាំង ការចាប់ប្រធានវិទ្យុសំបុកឃ្មុំ ការចាប់លោករ៉ុង-ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យជាដើម ដោយគ្រាន់តែបញ្ចេញមតិអំពីបញ្ហាព្រំដែន ។ ប៉ុន្តែបើប្រជាពលរដ្ឋប្តឹងរដ្ឋាភិបាលវិញ តុលាការតែងច្រានចោល មិនចាត់ការអ្វីទាំងអស់ ដោយយកលេសថា គ្មានភស្តុតាងគ្រប់គ្រាន់ ដូចករណីកណបក្សប្រឆាំងប្តឹងប្រធានរដ្ឋសភា និងប្តឹងនាយករដ្ឋមន្ត្រីជាដើម ។ ប្រជាពលរដ្ឋស្លូតត្រង់ដែលរងគ្រោះ គេពុំរកយុត្តិធម៌ឲ្យឡើយ អ្នកមានអំណាចប្រព្រឹត្តអំពើឧក្រិដ្ឋ តែងតែរួចខ្លួនពីសំណាញ់ច្បាប់ ដូចករណីប្រជាពលរដ្ឋនៅស្រុកអូរជ្រៅ ត្រូវប៉ូលិសប្រដាប់អាវុធបាញ់ស្លាប់អស់បួនប្រាំនាក់អំពីបញ្ហាដីធ្លី ត្រូវតុលាការខេត្តបដិ-សេធមិនរកយុត្តិធម៌ឲ្យអ្នករងគ្រោះឡើយ ដោយយកលេសថា គ្មានភស្តុតាងគ្រប់គ្រាន់ ។ ដូច្នេះអំណាចតុលាការខ្មែរពុំឯករាជ្យឡើយ តែងតែធ្វើតាមបំណងរបស់រដ្ឋាភិបាល ។

ដើម្បីបញ្ជាក់អំពីអំណាចច្បាប់ដែលអំណាចទាំងបីត្រូវគោរព យើងសូមដកស្រង់យកខ្លឹមសារនៃសន្និសិទមួយនៅទីក្រុងវ៉ាស៊ិនតោនឌីស៊ី ដែលធ្វើនៅថ្ងៃទី៩និងទី១០ខែវិច្ឆិកាឆ្នាំ២០០៥ ដែលផ្សាយដោយវិទ្យុអាស៊ីសេរី កាលពីថ្ងៃទី១៨វិច្ឆិកាក្រោមប្រធានបទថា ការគ្រប់គ្រងរដ្ឋដោយយកច្បាប់ជាធំ ។ សន្និសិទនេះរៀបចំដោយគណៈមេធាវីអាមេរិកាំង ។ សន្និសិទយល់ឃើញថា ការគ្រប់គ្រងរដ្ឋដែលមិនយកច្បាប់ជាធំ ជាមូលហេតុចំបងនាំឲ្យមានភាពក្រីក្រ អសន្តិសុខ និងអំពើពុករលួយ ។ ចំណែកការគ្រប់គ្រងរដ្ឋដោយយកច្បាប់ជាធំវិញ គឺជាឧបករណ៍ ឬជាវិធីសាស្ត្រដ៏សក្តិសិទ្ធិ ដើម្បីបង្កើតនូវសង្គមជាតិមួយឲ្យមានយុត្តិធម៌សង្គម បង្កើតឲ្យមានស្ថេរភាព ជំរុញឲ្យសេដ្ឋកិច្ចលូតលាស់ ព្រមទាំងអាចប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ភាពក្រីក្រ ជម្ងឺរាតត្បាត អំពើជួញដូរមនុស្ស និងភេរវកម្មឆ្លងដែន ។ វាគ្មិនម្នាក់នៃតុលាការកំពូលនៃប្រទេសហ្វីល្លីពីនមានប្រសាសន៍ថា ៖ នៅពេលដែលគេប្រើប្រាស់អំណាចតាមការកំណត់របស់ច្បាប់ នេះហើយជានីតិរដ្ឋ ។ ការយកច្បាប់ជាធំ គឺជាការកំណត់ព្រំដែន នូវការប្រើប្រាស់អំណាច មានន័យថាគ្មានមនុស្ស

ណាមួយ ទោះជាមន្ត្រីរាជការ មន្ត្រីយោធា ឬជនស៊ីវិលក៏ដោយ ក៏ពុំអាចមានសិទ្ធិទាមទារអំណាចណាមួយ ដែលច្បាប់មិនបានប្រគល់ឲ្យឡើយ ឬប្រើប្រាស់អំណាចណាមួយ ដែលផ្ទុយអំពីច្បាប់កំណត់ ។ វាគ្មិនម្នាក់ទៀត គឺអ្នកស្រីអនុប្រធានតុលាការកំពូលនៃសហរដ្ឋអាមេរិកមានប្រសាសន៍ថា ការពង្រឹងនីតិរដ្ឋត្រូវផ្អែកលើចំណុចពីរយ៉ាងគឺ ទីមួយ ភាពឯករាជ្យរបស់ចៅក្រម ក្នុងនាមជារូបវន្តបុគ្គល និងទីពីរ ភាពឯករាជ្យរបស់ស្ថាប័នតុលាការ ក្នុងនាមជានីតិបុគ្គល ។ ភាពឯករាជ្យរបស់ចៅក្រមក្នុងការបំពេញការងារ មានន័យថា ចៅក្រមអាចធ្វើសេចក្ដីសំរេចក្នុងការកាត់សេចក្ដី ដោយផ្អែកលើច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់នានា ដោយគ្មានការភ័យខ្លាចនូវការសងសឹក ការធ្វើឃាត ការបញ្ចុះបញ្ចៀវត្ស ។ ចំណែកភាពឯករាជ្យរបស់ស្ថាប័នតុលាការមានន័យថា ស្ថាប័នរដ្ឋាភិបាលនិងស្ថាប័នរដ្ឋសភា ត្រូវតែយល់ឲ្យច្បាស់ថាតុលាការជាស្ថាប័នមួយឯករាជ្យដាច់ដោយឡែក ដែលមានអំណាចសំរេចសេចក្ដីដោយមិនត្រូវមានការជ្រៀតជ្រែកពីរដ្ឋាភិបាល និងពីរដ្ឋសភាឡើយ ។ ប្រទេសមិនមែនជានីតិរដ្ឋ ឬប្រទេសដែលគ្រប់គ្រងមិនយកច្បាប់ជាធំ នឹងបណ្ដាលឲ្យមានការរំលោភសិទ្ធិមនុស្ស បណ្ដាលឲ្យមានភាពអត់ឃ្លាន និងរីកចំរើនអំពើពុករលួយ ។ ម្យ៉ាងទៀត ការមិនយកច្បាប់ជាធំ ធ្វើឲ្យក្រុមហ៊ុនជំនួញធំៗ នឹងមិនចូលទៅបោះវិនិយោគទុនរកស៊ីក្នុងប្រទេសទាំងឡាយណា ដែលពុំមានការគោរពឬអនុវត្តច្បាប់-កិច្ចសន្យា ឬពុំមានយន្តការផ្ដល់ការការពារដល់វិនិយោគិនទាំងនោះ ។ នេះជាឧប-សគ្គរាំងស្ទះដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងជំនួញ ឲ្យមានភាពក្រីក្រកាន់តែខ្លាំងឡើង ទោះបីមានជំនួយបរទេសជួយស្រោចស្រង់យ៉ាងណាក៏ដោយ ។ សន្និសិទជំរុញឲ្យប្រទេសក្នុងលោកគោរពច្បាប់ ។

ត្រង់មនុស្សទាំងឡាយ ជាពិសេសស្ថាប័នធំៗរបស់ប្រទេសត្រូវគោរពច្បាប់តាមផ្លូវអាណាចក្រនេះ ស្របនឹងផ្លូវពុទ្ធចក្រថា ពុទ្ធបរិស័ទដែលចូលកាន់ព្រះពុទ្ធសា-សនា ទោះបីមានជាតិត្រកូលខុសគ្នា ដោយសក្តិយសទ្រព្យសម្បត្តិ លុះអមកចូលកាន់ព្រះពុទ្ធសាសនា ត្រូវស្ថិតនៅក្រោមធម៌វិន័យរបស់ព្រះពុទ្ធដូចគ្នា តាមភេទជាគ្រហស្ថឬបុព្វជិត ។ បានសេចក្ដីថា មនុស្ស*កប់ឋានៈ អាចចូលកាន់គោរពព្រះពុទ្ធសាសនាបានទាំងអស់គ្នា ឲ្យតែមនុស្សគ្រប់រូបគោរពតាមធម៌វិន័យរបស់ព្រះពុទ្ធ ។ មនុស្សគ្រប់រូបដែលចូលកាន់ព្រះពុទ្ធសាសនា ត្រូវគោរពគ្នាទៅតាមគុណធម៌ខ្ពស់ទាបជាងគ្នា ទៅតាមកម្រិតធម៌វិន័យដែលខ្លួនបានប្រព្រឹត្ត ។ ដូច្នេះពុទ្ធបរិស័ទគ្រប់រូប ត្រូវស្ថិតនៅក្រោមធម៌វិន័យរបស់ព្រះពុទ្ធ ។

អំពីសន្ធិសញ្ញាបន្ថែមលើសន្ធិសញ្ញាឆ្នាំ១៩៨៥ ដែលរាជរដ្ឋាភិបាលខ្មែរបានចុះហត្ថលេខាជាមួយវៀតណាមក្នុងពេលថ្មីៗនេះ ជាបញ្ហាដែលប្រជាពលរដ្ឋខ្មែរក្នុងប្រទេសនិងក្រៅប្រទេស យកចិត្តទុកដាក់គិតគូរជាទីបំផុត ។ ការព្រួយបារម្ភខ្លាចបាត់បង់ទឹកដីតទៅទៀត របស់ប្រជាពលរដ្ឋខ្មែរជាការត្រឹមត្រូវ ព្រោះទឹកដីធ្លាប់បាត់ប

ង់ពីអតីតកាលដោយប្រទេសជិតខាង ។ ម៉្យាងទៀត រដ្ឋាភិបាលខ្មែរសព្វថ្ងៃ ជាកូនចៅប្រទេសជិតខាង ជាពិសេសប្រទេសវៀតណាម ។ ប្រជាពលរដ្ឋខ្មែរទូទៅយល់ថា សន្ធិសញ្ញាបន្ថែមនេះ ជាសន្ធិសញ្ញាសម្របច្បាប់ឲ្យសន្ធិសញ្ញាដែលមិនស្របច្បាប់ មិនត្រឹមតែឆ្នាំ១៩៨៥ទេ គឺឆ្នាំ១៩៧៩ ឆ្នាំ១៩៨២ និងឆ្នាំ១៩៨៣ផង ។ នេះជាផែនការដែលគេរៀបចំសន្ធិសញ្ញាទាំង៥នេះស្របច្បាប់ ព្រោះសន្ធិសញ្ញាទាំង៥នេះកើតឡើងពុំមានភាពស្មើគ្នា ដោយកងទ័ពវៀតណាមចូលមកឈ្លានពានប្រទេសកម្ពុជា ហើយកាន់កាប់ប្រទេសនេះ ហើយតែងតាំងរដ្ឋាភិបាលខ្មែរមួយដោយខ្លួនឯង ខ្មែរអ្នកស្នេហាជាតិនិងអង្គការសហប្រជាជាតិពុំទទួលស្គាល់ឡើយ ។ ដូច្នេះការចុះហត្ថលេខានេះ ទុកដូចជាចៅហ្វាយចុះហត្ថលេខាជាមួយកម្មករដែលមានទោស ។ សន្ធិសញ្ញាបែបនេះពុំមានយុត្តិធម៌ឡើយ ជាសន្ធិសញ្ញាខុសច្បាប់ ។ កិច្ចព្រមព្រៀងសន្តិភាពប្រទេសកម្ពុជានៅទីក្រុងប៉ារីសប្រទេសបារាំងឆ្នាំ១៩៩១ តម្រូវឲ្យលុបចោលទាំងអស់ នូវសន្ធិសញ្ញាដែលចុះហត្ថលេខាពេលសម័យវៀតណាមកាន់កាប់ប្រទេសកម្ពុជា ព្រោះជាសន្ធិសញ្ញាខុសច្បាប់ ។ គេមិនត្រូវយកមូលហេតុថា សន្ធិសញ្ញានោះមិនធ្វើឲ្យបាត់បង់ទឹកដី មិនរំលោភអធិបតេយ្យខ្មែរ និងបូរណភាពទឹកដីខ្មែរទេ ដូច្នេះត្រូវតែទុកដូច្នេះឡើយ គឺអ្វីដែលខុសច្បាប់ត្រូវតែលុបចោលជាដាច់ខាត ។ អ្នកដែលថាមិនបាត់បង់ទឹកដីដោយសន្ធិសញ្ញាខុសច្បាប់នេះ មានតែរដ្ឋាភិ-បាលខ្មែរមួយ ដែលលំអៀងទៅរកវៀតណាម ហើយអ្នកដែលហែអើដើម្បីបុណ្យស័ក្តិ និងអ្នកដែលមានការភ័យខ្លាចប៉ុណ្ណោះ ។ ចំណែកប្រជាពលរដ្ឋខ្មែរទូទៅនៅតែប្រឆាំងនឹងសន្ធិសញ្ញាបន្ថែមនេះ ព្រោមទាំងប្រទេសហត្ថលេខីទាំង១៩ប្រទេ-ស មានប្រទេសវៀតណាមផង ពេលនោះឲ្យលុបសន្ធិសញ្ញានោះចោល ។ ប៉ុន្តែរដ្ឋាភិបាលខ្មែរអាណត្តិទី១ឆ្នាំ១៩៩៣ អាណត្តិទី២ឆ្នាំ១៩៩៨ និងអាណត្តិទី៣ឆ្នាំ២០០៣ព្រមទាំងព្រះមហាក្សត្រផង ពុំព្រមប្រកាសលុបចោល ទុកឲ្យមានបញ្ហាមកទល់សព្វថ្ងៃ ។

បើរាជរដ្ឋាភិបាលខ្មែរឈរនៅលើប្រយោជន៍ខ្មែរ មិនបំរើបរទេស គួររដ្ឋាភិបា-លខ្មែរប្រមូលមតិខ្មែរទាំងអស់ ទាំងមតិស្របទាំងមតិប្រឆាំងមកដោះស្រាយ ដើ-ម្បីឲ្យមានឯកភាពជាតិ ។ បញ្ហាទឹកដីជាបញ្ហាធំណាស់ចំពោះជីវិតប្រទេស ត្រូវតែបើកឱកាសឲ្យប្រជាពលរដ្ឋបញ្ចេញមតិស្របតាមរដ្ឋធម្មនុញ្ញខ្មែរបច្ចុប្បន្ន ។ អ្នកស្នេហាជាតិ ស្នេហាទឹកដី ដែលបញ្ចេញមតិដើម្បីទឹកដីរបស់ខ្លួន ត្រូវរដ្ឋាភិបាលចាប់ចងយកទៅដាក់គុកដោយអំពើហឹង្សា ដែលផ្ទុយពីច្បាប់ ផ្ទុយពីឧត្តមគតិព្រះពុទ្ធសា-សនា ដោយយកលេសចោទថាបរិហារកេរ្តិ៍ខ្លួន តើរដ្ឋាភិបាលបែបនេះចាត់ជារដ្ឋាភិបាលអ្វី ? ដើម្បីឲ្យប្រជាពលរដ្ឋស្រឡាញ់និងគាំទ្រខ្លួន មិនត្រូវប្រព្រឹត្តដូច្នេះឡើយ ។ ត្រូវតែបើកសិទ្ធិឲ្យប្រជាពលរដ្ឋបញ្ចេញយោបល់ដោយគ្មានការគំរាមកំហែង ហើយរដ្ឋាភិបាលត្រូវយកយោបល់នោះទៅពិចារណា នេះជារបបប្រជាធិបតេយ្យ និង

ការគោរពសិទ្ធិមនុស្ស ហើយស្របតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ដែលយើងជាអ្នកគោរពព្រះពុទ្ធសាសនា ។ មិនទាន់ហួសពេលទេ ត្រូវតែដោះលែងអ្នកដែលត្រូវចាប់ ហើយត្រូវឈប់ចោទនិងឈប់តាមចាប់អ្នកដទៃទៀត ។ អំពើគំនុំសងសឹកនៅតែមានជាបន្តទៀត បើរដ្ឋាភិបាលនៅតែរំលោភច្បាប់ ។

ចំពោះតុលាការខ្មែរវិញ ប្រជាពលរដ្ឋខ្មែរសូមលើកដៃសំពះ សូមលោកតុលាការស្រឡាញ់យុត្តិធម៌ផង ព្រោះរយៈពេលកន្លងមក ប្រជាពលរដ្ឋសង្កេតឃើញថា លោកមានការលំអៀងខ្លាំងណាស់ បើរាជរដ្ឋាភិបាលមានបំណងយ៉ាងណា លោកធ្វើតាមភ្លាម ទោះបីចេញដីកាចាប់គេខុសច្បាប់ក៏ដោយ ក៏លោកហ៊ានប្រព្រឹត្តដោយឥតញញើត ដើម្បីតម្រូវចិត្តរដ្ឋាភិបាល ដូចជាចាប់លោកម៉ម-សូណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំ ដោយគ្មានដីកាហៅសាកសួរជាមុន ហើយចោទជាទោសមជ្ឈឹមដាក់ទោសឧក្រិដ្ឋ ហើយករណីលោករ៉ុង-ឈុនក៏មានលក្ខណៈដូចគ្នា ។ គ្រាន់តែគេសុំឲ្យនៅក្រៅឃុំ ក៏លោកមិនព្រមអនុញ្ញាតិឲ្យគេ ។ ផ្ទុយទៅវិញ បើប្រជាពលរដ្ឋប្ដឹងរដ្ឋាភិបាលវិញ លោកបដិសេធមិនលើកយកមកជំនុំជំរះ ដោយយកមូលហេតុថាគ្មានភស្តុតាងគ្រប់គ្រាន់ ។ សូមសំណូមពរ សូមលោកឈប់សាងអំពើបាបកម្មបែបនេះតទៅទៀតទៅ ។ អំពើបែបនេះរបស់លោក តាមផ្លូវព្រះពុទ្ធសាសនាមានទោសធ្ងន់ណាស់ កម្មពៀរដែលលោកបានប្រព្រឹត្តទៅលើអ្នកស្លូតត្រង់គ្មានទោសពៃរ៍ នឹងផ្ដល់ផលឲ្យលោកវិញនៅពេលខាងមុខនេះ ។ បើលោកចៅក្រមមេធាវីយល់ថាបានជាលោកប្រព្រឹត្តដូច្នេះ ព្រោះការភ័យខ្លាច លោកអាចមានវិធីជ្រើសរើសមួយ គឺការឈប់ពីតំណែង ជាជាងលោកនៅតែប្រព្រឹត្តខុសលក់ឧត្តមគតិដ៏ល្អ និងចំណេះវិជ្ជាដែលលោកខំសិក្សាឲ្យគេ ។ ប្រទេសមួយដែលមានស្ថេរភាពនិងតុល្យភាពអំណាចមានតែតុលាការទេដែលចេះថ្លឹងថ្លែងពិនិត្យពិចារណារកការពិត ដោយមិនលំអៀងស្ថិតនៅលើគតិយុត្តិធម៌ ។ បើលោកតុលាការអនុវត្តលំអៀងទៅរករដ្ឋាភិបាល តើត្រង់ណាទៅដែលគេហៅថា ទាំងអស់គ្នា ទាំងអ្នកធំទាំងអ្នកតូច ត្រូវតែមានសមភាពចំពោះមុខច្បាប់ដូចគ្នា ។ តុលាការបែបនេះ គេអាចពោលថា ជាតុលាការរបស់រាជរដ្ឋាភិបាល ពុំមែនជាតុលាការរបស់ជាតិខ្មែរទាំងមូលឡើយ ។

ការបាត់បង់ដីកម្ពុជាក្រោម បាត់បង់កោះត្រល់ កោះក្រចកសេះ និងទឹកដីខ្លះទៀតតាមព្រំដែនខ្មែរ-វៀតណាម យើងគ្រាន់តែទទួលដឹងថា មត៌កទាំងនោះរបស់ខ្មែរបានត្រូវវៀតណាមកាន់កាប់ ។ ប៉ុន្តែបើសន្ធិសញ្ញាបន្ថែមទៅលើសន្ធិសញ្ញាខុសច្បាប់នោះទទួលស្គាល់ថា មត៌កទាំងនោះជារបស់វៀតណាម នេះជាអនុសញ្ញាបិទផ្លូវ មិនឲ្យខ្មែរមានសិទ្ធិទាមទារទៅថ្ងៃក្រោយ ។ បើអនុសញ្ញានេះមានន័យដូច្នេះ ប្រជាពលរដ្ឋខ្មែរនឹងប្រឆាំងជាដាច់ខាត ព្រោះខ្មែរនៅតែមានសិទ្ធិទាមទារទឹកដីរបស់ខ្លួន ដែលបានបាត់បង់ទៅតាមផ្លូវច្បាប់ទៅអនាគតទៀត នេះមិននិយាយពីអនុស-ញ្ញានោះដែលត្រូវមតិខ្មែរអ្នកស្នេហាជាតិទូទៅសង្ស័យថា មានបាត់បង់ទឹកដីក្រៅពី

នេះទៀតផង ។ តាមដីគោកមានបង្គោលម៉ែត្រនៅខេត្តព្រៃវែង ទើបនឹងបោះនៅឆ្នាំ ១៩៨៦ ហើយមានកន្លែងខ្លះបោះនៅឆ្នាំ១៩៨៨ គឺបោះនៅពេលដែលកងទ័ពវៀត-ណាមកំពុងកាន់កាប់ប្រទេសកម្ពុជា ដូច្នេះការបោះបង្គោលនោះ ពុំមានយុត្តិធម៌មកកម្ពុជាឡើយ កម្ពុជាអាចបាត់បង់ទឹកដី ។ បើយកផែនទីអាមេរិកាំងសម័យសង្គ្រាមវៀតណាម ក៏ពុំត្រឹមត្រូវដែរ ព្រោះអាមេរិកាំងគូរដើម្បីទម្លាក់គ្រាប់បែក ដើម្បីកុំឲ្យប៉ះពាល់ដល់ប្រទេសកម្ពុជា អាចគូរបង្ខិតចូលមកដីខ្មែរ ដើម្បីទម្លាក់គ្រាប់បែកទៅកុំឲ្យថា ដីខ្មែរជៀសវាងការថ្កោលទោសច្បាប់អន្តរជាតិ ។ គួរយកផែនទីខ្នាត១/១០០ ០០០ ធ្វើនៅចន្លោះឆ្នាំ១៩៦៣=១៩៦៩ ដូចមាននៅក្នុងរដ្ឋធម្មនុញ្ញខ្មែរត្រង់មាត្រា២ចែងស្រាប់ ។

អំពីស្ថាប័នព្រះមហាក្សត្រ ត្រង់មាត្រា៨ចែងថា ព្រះមហាក្សត្រទ្រង់ជាអ្នកធា-នាឯករាជជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ និងការគោរពសន្ធិសញ្ញាអន្តរជាតិ ។ ត្រង់មាត្រាខាងលើនេះ ព្រះមហាក្សត្រមានតួនាទីធានាការពារទឹកដីប្រទេសកម្ពុជាមិនឲ្យបាត់បង់ គេនៅចាំមើល តើព្រះមហាក្សត្រសំរេចព្រះទ័យព្រះហត្ថលេខាឬពុំឡាយ ក្រោយពេលដែលសភានិងព្រឹទ្ធសភាធ្វើសច្ចានុម័តហើយ ។ បើតាមមតិប្រជាពលរដ្ឋ បើព្រះមហាក្សត្រពុំឡាយព្រះហត្ថលេខា ប្រជាពលរដ្ឋទូទៅមានចិត្តរីករាយណាស់ ហើយនិងគោរពស្រឡាញ់ព្រះមហាក្សត្ររបស់ខ្លួន កាន់តែខ្លាំងឡើងថែមទៀត ដោយចាត់ទុកថា ជាព្រះមហាក្សត្រការពារបូរណភាពទឹកដីរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញត្រង់មាត្រា២ដូចចែងខាងលើ ។ ផ្ទុយទៅវិញ បើព្រះមហាក្សត្រខ្មែរយល់ព្រមចុះព្រះហត្ថលេខា ប្រជាពលរដ្ឋទូទៅទាំងក្នុងប្រទេសនិងក្រៅប្រទេសមានការខកចិត្ត និងកើតទុក្ខក្រៀមក្រំយ៉ាងខ្លាំង ។ យើងយល់ថា បើព្រះមហាក្សត្រគិតប្រយោជន៍ជាតិ ប្រយោជន៍ទឹកដីជាធំ បើព្រះអង្គយល់ថា ការចុះព្រះហត្ថលេខានេះនាំឲ្យបាត់បង់ទឹកដី ព្រះអង្គពិតជាពុំចុះព្រះហត្ថលេខាឡើយ ស្របតាមព្រះបិតា គឺព្រះអតីតព្រះមហាក្សត្រ គឺព្រះករុណាសម្តេចនរោត្តម-សីហនុ ក៏ព្រះអង្គប្រឆាំងនឹងអនុសញ្ញាបន្ថែមនេះដែរ ។៚

❑ ❑

❑